
Kids of Destiny
Reaching the Next Generation
www.kidsofdestiny.org

## 4.07 ព្រះយេស៊ូវគំហែងព្យុះឲ្យស្ងប់ស្ងាត់

ថ្ងៃមួយព្រះយេស៊ូវទ្រង់បានបង្រៀនពេញមួយថ្ងៃ។ នៅតែមានមនុស្សជាច្រើនចង់ស្តាប់សេចក្តីបង្រៀនរបស់ទ្រង់ ហើយចង់រៀនពីទ្រង់ ពីរបៀបរស់នៅដែលគាប់ព្រះហឫទ័យព្រះអម្ចាស់។ នៅថ្ងៃនេះ ទ្រង់បានតាំងបង្រៀននៅសមុទ្រម្តងទៀត។ ដោយសារតែមានមនុស្សទាំងហ្វូងមូលគ្នាមកឯទ្រង់ ដល់ម្លេះបានជាទ្រង់យាង ចុះទៅគង់ក្នុងទូកមួយ ដើម្បីឲ្យមនុស្សគ្រប់គ្នាបានឃើញ និងបានស្តាប់។ នេះមិនមែនជាលើកទីមួយទេ ដែលទ្រង់បានមានបន្ទូលទៅកាន់ប្រជាជនពីទូក! ទ្រង់មានសេចក្តីបង្រៀនជាច្រើន ដើម្បីប្រាប់ពួកគេនៅថ្ងៃនោះ។ ទ្រង់បានបង្រៀនពីសេចក្តីជាច្រើន តាមរបៀបដែលមនុស្សទាំងអស់អាចស្តាប់ និងយល់ច្បាស់ ។ ទ្រង់មិនចង់ឲ្យមេរៀនរបស់ទ្រង់ពិបាកយល់សម្រាប់ពួកគេទេ។

ក្រោយមកនៅពេលដែលទ្រង់នៅតែម្នាក់ឯង ជាមួយសិស្សរបស់ទ្រង់ នោះទ្រង់បានបង្រៀនសេចក្តីនោះម្តងទៀត ប៉ុន្តែទ្រង់បានពន្យល់ពួកគេដោយលម្អិតបន្ថែមទៀត។ ដោយសារតែពួកគេដើរតាមទ្រង់ គ្រប់ទីកន្លែងដែលទ្រង់យាងទៅ ទ្រង់បានមានបន្ទូល និងបង្រៀនគេជាច្រើនដង។ ពួកគេអាចយល់កាន់តែច្បាស់ពីអ្វីដែលព្រះយេស៊ូវបានមានបន្ទូល។ បន្ទាប់មក នៅពេលថ្ងៃដដែលទ្រង់បានមានបន្ទូលទៅពួកគេថា៖ «ចូរធ្វើដំណើរឆ្លងសមុទ្រទៅត្រើយម្ខាង»។ ពួកគេអង្គុយក្នុងទូកកន្លែងដែលព្រះអង្គបានបង្រៀន ហើយទូកឯទៀតៗ ក៏ចូលមកក្នុងសមុទ្រដែរ ។ នៅពេលដែលពួកគេឆ្លងកាត់សមុទ្រព្យុះដ៏ធំមួយបានចាប់ផ្តើម ដែលមានខ្យល់បក់បោកយ៉ាងខ្លាំង។ ខ្យល់ចាប់ផ្តើមបង្កើតជារលកធំៗ នៅក្នុងទឹក។ បន្ទាប់មករលកក៏ចាប់បោកបក់ទូក ។

វាហាក់ដូចជាគ្រោះថ្នាក់ណាស់! ទូកអាចនឹងលិច! នេះបានធ្វើឲ្យពួកសិស្សភ័យខ្លាច ហើយពួកគេបានទៅដាស់ព្រះយេស៊ូវ ដែលកំពុងផ្ទំលក់យ៉ាងស្កប់ស្កល់។ គេទូលសួរព្រះយេស៊ូវថា៖ «លោកគ្រូ! តើទ្រង់មិនព្រួយបារម្ភអំពីខ្យល់ព្យុះនេះទេឬ? យើងអាចនឹងលិច! ព្រះយេស៊ូវទ្រង់បានផ្ទំលក់យ៉ាងស្កប់ស្កល់ ។ ទ្រង់បានចំណាយពេលបង្រៀនពេញមួយថ្ងៃ ហើយទ្រង់នឿយហត់ជាខ្លាំង ។ ទ្រង់មិនដែលព្រួយបារម្ភអំពីព្យុះនោះទេ។ ទោះយ៉ាងណាក៏ដោយ ដោយសារតែពួកសិស្សបានដាស់ទ្រង់ពីដំណេករបស់ទ្រង់ ទ្រង់បានមានបន្ទូលទៅកាន់ព្យុះ ហើយបានគំហែងខ្យល់ និងរលកឲ្យនៅស្ងៀម។ ទ្រង់មានបន្ទូលថា "ចូរស្ងៀម។ នៅស្ងៀម" ។

ភ្លាមៗបន្ទាប់ពីទ្រង់បានមានបន្ទូលដូច្នោះខ្យល់ក៏ឈប់ ។ អ្វីៗទាំងអស់បានស្ងប់ស្ងាត់ឡើងវិញ ។ ព្រះយេស៊ូវបែរទៅរកសិស្ស ហើយមានព្រះបន្ទូលថា៖ «ហេតុអ្វីបា នជាអ្នករាល់គ្នាភិតភ័យដូច្នេះ? ហេតុអ្វីបានជាអ្នកគ្មានសេចក្តីជំនឿ?" ពួកសិស្សងឿងឆ្ងល់ចំពោះអ្វី ដែលពួកគេបានឃើញ ហើយថែមទាំងភ័យខ្លាចទៀតផង ។ ពួកគេនិយាយគ្នាថា៖ «តើអ្នកនេះជានរណា? សូម្បីតែខ្យល់ និងរលកសមុទ្រក៏ស្តាប់បង្គាប់ទ្រង់ដែរ" ទោះបីជាពួកគេបានឃើញព្រះយេស៊ូវធ្វើការអស្ចារ្យផ្សេងទៀតក៏ដោយ ដោយការមើលខ្យល់ និងរលកស្តាប់បង្គាប់ទ្រង់ គឺអស្ចារ្យណាស់ ។ ក្រោយមកពួកគេបានដឹងថា ព្រះយេស៊ូវគឺមានអំណាចជាងធម្មជាតិទៅទៀត។ **(ម៉ាកុស ៤)**

## 4.07 ព្រះយេស៊ូវគំហែងព្យុះឲ្យស្ងប់ស្ងាត់ សេចក្តីណែនាំសម្រាប់គ្រូបង្រៀន កំណត់សំគាល់

១) ព្រះយេស៊ូវទ្រង់បានបង្រៀន និងប្រាប់ពីសេចក្តីផ្សេងៗជារៀងរាល់ថ្ងៃ។ ទ្រង់បានមានបន្ទូលពីសេចក្តីជាច្រើន អ្នកនឹងដឹងពីអារម្មណ៍របស់អ្នកនៅពេលដែលអ្នករវល់ពេញមួយថ្ងៃ!តើអ្នកដឹងទេថា ឪពុកម្តាយរបស់អ្នកមានអារម្មណ៍យ៉ាងណាបន្ទាប់ពីពួកគាត់បានខិតខំធ្វើការងារពេញមួយថ្ងៃ? ជាច្រើនលើកប្រសិនបើមាននរណាម្នាក់នឿយហត់ខ្លាំង ពួកគេត្រូវការសម្រាក។

២) ព្រះយេស៊ូវបានបង្រៀនរឿងម្តងទៀតដោយពន្យល់លម្អិតបន្ថែមទៀតនូវមេរៀនខ្លះ ដែលពួកគេត្រូវរៀនពីរឿងទាំងនេះ។

៣) នៅពេលក្រោយមក ពួកគេបានយកទូកដែលពួកគេបានជិះចេញទៅសមុទ្រដើម្បីទៅត្រើយម្ខាង។ បន្ទាប់មកព្យុះដ៏ធំមួយបានចាប់ផ្តើម។ តើអ្នកធ្លាប់ជួបព្យុះដ៏ធំដែរឬទេ? តើទឹកភ្លៀងបានធ្លាក់ចុះខ្លាំង ហើយមានខ្យល់បក់ខ្លាំងដែលពិតជាគួរឱ្យខ្លាចមែនដែរឬទេ?

៤) ព្រះយេស៊ូវកំពុងផ្ទំលក់ តែពួកសិស្សរបស់ទ្រង់បានភ្ញាក់ឡើង ហើយពួកគេមានការភ័យខ្លាចដោយសារព្យុះដ៏ធំដែលបានកើតឡើង ។

៥) ព្រះយេស៊ូវទ្រង់បានមានបន្ទូលទៅកាន់ខ្យល់ និងរលក ហើយពួកគេបានស្តាប់តាមទ្រង់។ ភ្លាមនោះខ្យល់ព្យុះក៏ឈប់ – ទឹកក៏ស្ងប់ហើយខ្យល់ក៏ឈប់បក់បោក។

**សំណួរ:**

១) ហេតុអ្វីបានជាព្រះយេស៊ូវហត់នឿយថ្ងៃនោះ?

២) តើព្រះយេស៊ូវ និងពួកសិស្សរបស់ព្រះអង្គ បានធ្វើដំណើរតាមទូកទៅឯណា?

៣) តើព្រះយេស៊ូវទ្រង់កំពុងធ្វើអ្វី នៅពេលព្យុះបានចាប់ផ្តើម?

៤) តើពួកសិស្សមានអារម្មណ៍យ៉ាងណា?

៥) តើពួកសិស្សមានអារម្មណ៍យ៉ាងដូចម្តេច បន្ទាប់ពីព្រះយេស៊ូវ ទ្រង់បានគំរាមឲ្យព្យុះស្ងប់ស្ងាត់?

**ចម្លើយ:**

២) ព្រះយេស៊ូវបានបង្រៀនបណ្តាជនពេញមួយថ្ងៃ។

៣) ពួកគេបានទៅត្រើយម្ខាងទៀតនៃសមុទ្រ។

៤) ព្រះយេស៊ូវកំពុងផ្ទំលក់។

៥) ពួកសិស្សភ័យខ្លាច។

៦) ពួកសិស្សបានងឿងឆ្ងល់យ៉ាងខ្លាំង ដែលសូម្បីតែខ្យល់ និងរលកធម្មជាតិ ក៏ស្តាប់បង្គាប់ទ្រង់ដែរ។

Kids of Destiny
Reaching the Next Generation



www.kidsofdestiny.org